សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា
Coalition of Cambodian Apparel Workers Democratic Union
ផ្ទះលេខ ២,៣G ផ្លូវលេខ២៦BT. ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Tel: 012 998 906 / 012 709 509 / 085 617 788 Website: www.ccawdu.org
Email: c.cawdu@online.com.kh, c.cawdu@clccambodia.org
CLC-C.CAWDU

# សេចក្តីថ្លែងការណ៍
# របស់
# សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)

## យុត្តិធម៌មានន័យថាការទទួលបានប្រាក់ឈ្នួលសមរម្យ

ពួកយើងជាកម្មករកាត់ដេរនៅកម្ពុជាដែលមានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ហៅកាត់ថា C.CAWDU ជាអ្នកតំណាងសូមប្រកាសថា ប្រាក់ឈ្នួលអប្បបរមាដែល គណៈកម្មាធិការប្រឹក្សាការងារបានសម្រេចផ្តល់ជូនកម្មករនិយោជិត ៨០ ដុល្លាក្នុងមួយខែ គឺពុំទាន់គ្រប់គ្រាន់អាចបំពេញតម្រូវការមូលដ្ឋានរបស់កម្មករនិយោជិតបានឡើយ។ ពួកយើងកំពុងតែអំពាវនាវដល់ក្រុមហ៊ុនស្លាកសញ្ញាជាច្រើន ដើម្បីធានាឲ្យបាននូវប្រាក់ឈ្នួលអប្បបរមា ១០០ដុល្លា ក្នុងមួយខែសម្រាប់កម្មករកាត់ដេរនៅកម្ពុជាដែលផលិតសម្លៀកបំពាក់ក្នុងនាមរបស់ពួកគេ។

របាយការណ៍រួមមួយដែលប្រកាសដោយសាលាច្បាប់ស្ទែនហ្វត និងសមាគមសិទ្ធិកម្មករបានថ្លែងថា (កម្មករកម្ពុជានៅតែទទួលរងការឈឺចាប់នូវការធ្លាក់ចុះប្រាក់ឈ្នួលជាក់ស្តែង ចំនួន ១៦.៦ ភាគរយ សម្រាប់ការងារទៀងទាត់ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១០ ដែលការធ្លាក់ចុះនឹងអាចកើនឡើងដល់ ៣០ ភាគរយនៅត្រឹមឆ្នាំ២០១៤)[1]។ ការធ្លាក់ចុះនេះត្រូវបានកំណត់យ៉ាងច្បាស់ថា ប្រាក់ឈ្នួលអប្បបរមាគឺមានសារៈសំខាន់ណាស់ក្នុងការកម្រិតប្រាក់ឈ្នួលសមរម្យក្នុងឆ្នាំ ២០០០ បើធៀបទៅនឹងសព្វថ្ងៃ។ យោងតាមការសិក្សារបស់អង្គការការងារអន្តរជាតិ និងវិទ្យាស្ថានសិក្សាដើម្បីអភិវឌ្ឍកម្ពុជាបានសន្និដ្ឋានថាប្រាក់ឈ្នួលសមរម្យពិតប្រាកដសម្រាប់កម្មករកាត់ដេរកម្ពុជាគួរតែទទួលបាន ១០៤ ដុល្លា ក្នុងមួយខែ។ ប្រាក់ឈ្នួលនេះ នឹងអាចផ្គត់ផ្គង់តម្រូវការចាំបាច់ជាមូលដ្ឋានបានដូចជា អាហារ ជួលផ្ទះ និងអាចសន្សំទុកបានខ្លះនៅពេលមានអាសន្ន ដូចជាករណីសមាជិកគ្រួសារណាមួយទទួលមរណៈភាពជាដើម។

ថ្មីៗនេះមានកម្មករដួលសន្លប់ ជាច្រើនដែលធ្វើឲ្យកម្មករធ្វើការក្នុងវិស័យឧស្សាហកម្មកាត់ដេរបានជួបនូវបញ្ហាមួយក្នុងបញ្ហាជាច្រើនដែលបញ្ហានោះគឺ ទទួលបានប្រាក់ឈ្នួលទាប។ ចាប់តាំងពីខែ មិថុនា ឆ្នាំ២០១០ មកយើងឃើញមានគ្រោះថ្នាក់នៃការដួលសន្លប់របស់កម្មករបីទៅបួនលើកក្នុងករណីផ្សេងៗគ្នា ដែលក្នុងនោះមានកម្មករដួលសន្លប់ក្នុងរោងចក្រកាត់ដេរ និងរោងចក្រស្បែកជើងចំនួន ១៦រោងចក្រនៅកម្ពុជា។ សរុបកម្មករដួលសន្លប់ប្រមាណ ៤, ០០០ នាក់[2]។ រដ្ឋលេខាធិការក្រសួងការងារកម្ពុជា លោក ម៉ម

---

[1] "Monitoring in the Dark", International Human Rights and Conflict Resolution Clinic Stanford Law School and Workers Rights Consortium, 2013

[2] Presentation: *Mass Faintings and Cambodia's Wage Development*, Peoples Tribunal on Asia Minimum Floor Wage, Cambodia.